ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

# របាយការណ៍កិច្ចប្រជុំ
# ក្រុមប្រឹក្សាបច្ចេកទេសអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

**១. ថ្ងៃ ខែ ឆ្នាំ៖** ថ្ងៃអង្គារ ១២រោច ខែផល្គុន ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
រាជធានីភ្នំពេញ ថ្ងៃទី២៥ ខែមីនា ឆ្នាំ២០២៥។

**២. ទីកន្លែង៖** នៅអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងតាមប្រព័ន្ធនិម្មិត(Zoom)។

**៣. ប្រធាន និងសមាសភាពចូលរួម ៖**

- ប្រធានអង្គប្រជុំ **ឯកឧត្តមបណ្ឌិត ឈឹម ឃិនជារ៉េត** អគ្គលេខាធិការអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។
- សមាសភាពចូលរួមមាន សមាជិក សមាជិកាថ្នាក់បច្ចេកទេសអន្តរក្រសួង ស្ថាប័ន រាជធានី ខេត្ត និង អង្គការសង្គមស៊ីវិលពាក់ព័ន្ធ ដែលចូលរួមផ្ទាល់ចំនួន៣៦រូប និងតាមប្រព័ន្ធនិម្មិតចំនួន៣៧រូប សរុបចំនួន៧៣រូប។

**៤. របៀបវារៈ៖**

- មតិស្វាគមន៍ និងគោលបំណងនៃកិច្ចប្រជុំដោយ **ឯកឧត្តមបណ្ឌិត ឈឹម ឃិនជារ៉េត** អគ្គលេខាធិការ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងជាប្រធានក្រុមប្រឹក្សាបច្ចេកទេស។
- បទបង្ហាញស្តីពី "ការអនុវត្តសេវាផ្តល់ឱសថបង្ការការឆ្លងមេរោគអេដស៍ (PrEP) នៅក្នុងព្រះរាជាណាចក្រកម្ពុជា"។ បង្ហាញដោយ **លោកវេជ្ជ. ង៉ូវ បូរ៉ា** អនុប្រធានមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ នៃក្រសួងសុខាភិបាល។
- មតិបូកសរុប និងបិទកម្មវិធីដោយ **ឯកឧត្តមបណ្ឌិត ឈឹម ឃិនជារ៉េត** អគ្គលេខាធិការ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។

**៥. លទ្ធផល ៖**

ជាកិច្ចចាប់ផ្តើម **ឯកឧត្តមបណ្ឌិត ឈឹម ឃិនជារ៉េត អគ្គលេខាធិការអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍** បានបើកនូវកិច្ចប្រជុំក្រុមប្រឹក្សាបច្ចេកទេសអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍លើកទី៣ ឆ្នាំ២០២៥ បាន ថ្លែងនូវមតិស្វាគមន៍ដល់អង្គប្រជុំ និងសរសើរក្រុមការងារនៃគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ក្រសួង ស្ថាប័ន រាជធានី ខេត្ត ដែលបានប្រឹងប្រែងចូលរួមក្នុងការអនុវត្តការឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ កន្លងមក ដែលបង្កឱ្យអត្រាប្រេវ៉ាឡង់មេរោគអេដស៍នៅកម្ពុជា បានធ្លាក់ចុះជាបន្តបន្ទាប់មកនៅត្រឹមតែ

០,៥ % នៅឆ្នាំ២០២៣។ ទន្ទឹមនឹងនេះដែរ **ឯកឧត្តមបណ្ឌិត** ក៏បានលើកឡើងពីផលប៉ះពាល់នៃការកាត់បន្ថយហិរញ្ញប្បទានពីខាងក្រៅ។

**គោលបំណងនៃកិច្ចប្រជុំមានដូចខាងក្រោម៖**

១- បច្ចុប្បន្នភាពនៃមេរោគអេដស៍ និងជំងឺអេដស៍ លើពិភពលោក និងកម្ពុជា។

២- ការឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

៣- ការអនុវត្តសេវាផ្តល់ឱសថបង្ការការឆ្លងមេរោគអេដស៍(PrEP)។

៤- ផ្សេងៗ

ដំណើរការនៃកិច្ចប្រជុំមាន៖

**ឯកឧត្តមបណ្ឌិត** អគ្គលេខាធិការ មានប្រសាសន៍ជូនអង្គប្រជុំឱ្យបានជ្រាបថា កិច្ចប្រជុំថ្ងៃនេះ បានផ្តោតលើការប្រើប្រាស់ឱសថប្រិព(PrEP) ដែលជាថ្នាំការពារការចម្លងមេរោគអេដស៍ ដល់សមាជិកសមាជិកា បានយល់ដឹងពីការប្រើប្រាស់ និងបានផ្សព្វផ្សាយបន្តដើម្បីការពារការចម្លងថ្មី ដើម្បីឈានដល់គោលដៅ៩៥ ៩៥ ៩៥។ ការងារឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍នៅកម្ពុជាធ្វើឡើងជាពហុវិស័យដោយរួមបញ្ចូលទាំងផ្នែកសុខាភិបាល និងទាំងផ្នែកមិនមែនសុខាភិបាល ដែលតម្រូវឱ្យយើងបន្តប្រឹងប្រែងរួមគ្នាសម្រេចនូវគោលដៅដែលបានកំណត់ក្នុងគោលនយោបាយជាតិបញ្ចប់អេដស៍ និងចីរភាពកម្មវិធីអេដស៍សម្រាប់ឆ្នាំ២០២៣-២០២៨ របស់រាជរដ្ឋាភិបាល ក្រោមមគ្គុទេសក៍ដ៏ខ្ពង់ខ្ពស់បំផុត សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា។

**លោកវេជ្ជ. ង៉ូវ បូរ៉ា** អនុប្រធានមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ នៃក្រសួងសុខាភិបាលបានបង្ហាញពី "ការអនុវត្តសេវាផ្តល់ឱសថបង្ការការឆ្លងមេរោគអេដស៍ (PrEP) នៅក្នុងព្រះរាជាណាចក្រកម្ពុជា"។ **លោកវេជ្ជបណ្ឌិត** បានជម្រាបដល់អង្គប្រជុំថា មកដល់ចុងឆ្នាំ២០០៤នេះ មានអ្នកផ្ទុកមេរោគអេដស៍បានមកទទួលសេវាថែទាំ និងព្យាបាលជំងឺអេដស៍មានចំនួនប្រមាណ ៧ម៉ឺននាក់ហើយ។ តាមការប៉ាន់ប្រមាណបែបវិទ្យាសាស្ត្រក្នុងឆ្នាំ២០២៣ មានអ្នកផ្ទុកមេរោគអេដស៍នៅកម្ពុជាមានប្រមាណជា ៧៦,០០០នាក់ ក្នុងនោះមានអ្នកឆ្លងថ្មីប្រមាណជា ១,២០០នាក់ ដែលភាគច្រើនជាក្រុមប្រជាជនគន្លឹះ ដូចជា ក្រុមស្ត្រីបម្រើការនៅសេវាកម្សាន្តសប្បាយ ក្រុមបុរសរួមភេទជាមួយបុរស ក្រុមបំប្លែងភេទ ក្រុមប្រើប្រាស់គ្រឿងញៀន និងក្រុមអ្នកចាក់គ្រឿងញៀន ដែលចំនួនសរុបប្រមាណជា ១៦ម៉ឺននាក់។

វិធីសាស្ត្រផ្តល់ឱសថបង្ការការឆ្លងមេរោគអេដស៍ ដោយសង្កាត់ធ្ងន់លើសេវា PrEP គឺប្រើប្រាស់ឱសថ។ ដូចនេះ មុននឹងប្រើប្រាស់ត្រូវតែអនុវត្តតាមនិយាមនៃការប្រើប្រាស់សេវា PrEP ដែលត្រូវបានអនុម័តដោយក្រសួងសុខាភិបាល។ មកដល់ខែកុម្ភៈ ឆ្នាំ២០២៥នេះ កម្ពុជាមានសេវា PrEP ចំនួន ៥៥កន្លែង ដែលមានអ្នកបានទទួលសេវា PrEP ចំនួន ៣៤,០០០នាក់ ក្នុងនោះ បុរសរួមភេទជាមួយបុរស ៦៩% ក្រុមបំប្លែងភេទ ១៣% ស្ត្រីបម្រើនៅសេវាកម្សាន្តសប្បាយ ១៥% និងដៃគូរបស់អ្នកផ្ទុកមេរោគអេដស៍ ឬក្រុម

ប្រជាជនគន្លឹះ ៣%។ **លោកវេជ្ជបណ្ឌិត** បានបញ្ជាក់ពីសកម្មភាពមួយចំនួនដែលគាំទ្រដល់ការអនុវត្ត PrEP ក្នុងការឈានទៅសម្រេចបាននូវគោលដៅកំណត់ និងវិធីសាស្ត្រនៃការប្រើប្រាស់ PrEP ព្រមទាំងផែនការប្រចាំឆ្នាំសម្រាប់ការអនុវត្ត។

បន្ទាប់ពីពិភាក្សាយ៉ាងផុលផុស ជាចុងក្រោយ **ឯកឧត្តមបណ្ឌិត** បានផ្តល់នូវអនុសាសន៍ដល់កិច្ចប្រជុំដូចខាងក្រោម៖

- បន្តការអនុវត្តនូវយន្តការបង្ការ ដូចជាសេវា PrEP ការព្យាបាលជាការបង្ការ ( ម=ម ) ។ល។
- ពង្រីក និងពង្រឹង សេវាធ្វើតេស្តរកមេរោគអេដស៍។
- ពង្រីក និងពង្រឹង ឱ្យមានការផ្លាស់ប្តូរឥរិយាបទនៃការប្រព្រឹត្តប្រឈម។
- ជំរុញ និងពង្រឹងនូវប្រព័ន្ធផ្សព្វផ្សាយ ក្នុងការឆ្លើយតបនឹងមេរោគអេដស៍។
- ជំរុញនូវការផ្សព្វផ្សាយសារាចរណែនាំលេខ០០១ស.ណ.នស្តីពីការលើកកម្ពស់សកម្មភាពចូលរួមឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ របស់ក្រសួងទេសចរណ៍។
- សំណូមពរដល់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ជួយផ្តល់លេខបន្ទាន់មួយខ្សែ ( Hotline ) ដោយឥតគិតថ្លៃពីគ្រប់ប្រព័ន្ធសេវាទូរស័ព្ទ។
- សុំសមាជិកក្រុមប្រឹក្សាបច្ចេកទេសនៅថ្នាក់ក្រសួង ស្ថាប័ន អញ្ជើញចូលរួមដោយផ្ទាល់។

ចុងបញ្ចប់ **ឯកឧត្តមបណ្ឌិត** អគ្គលេខាធិការ ប្រធានអង្គប្រជុំក៏បានបន្ថែមថា ការងារបង្ការ គឺជាយុទ្ធសាស្ត្រចម្បងក្នុងការងារសុខភាពសាធារណៈ ហើយក៏ជាមូលដ្ឋានគ្រឹះក្នុងការឆ្ពោះទៅសម្រេចនូវគោលដៅការគ្របដណ្តប់សុខភាពសកល។ **ឯកឧត្តមបណ្ឌិត** បានជំរុញលើកទឹកចិត្តឱ្យសមាជិកក្រុមប្រឹក្សាបច្ចេកទេសដែលអនុវត្តផ្ទាល់លើការងារអេដស៍ លើកពីបទពិសោធន៍រួមជាមួយនឹងឧបសគ្គនានា ក្នុងការអនុវត្តការងារប្រយុទ្ធនឹងមេរោគអេដស៍ និងជំងឺអេដស៍ ដើម្បីរកវិធីសាស្ត្រឆ្លើយតបឱ្យបានទាន់ពេល និងមានប្រសិទ្ធភាពខ្ពស់។

សម្រាប់កិច្ចប្រជុំបន្ទាប់នឹងកំណត់យក នៅថ្ងៃព្រហស្បតិ៍ ១២រោច ខែចេត្រ ឆ្នាំម្សាញ់ សប្តស័ក ព.ស. ២៥៦៨ ត្រូវនឹងថ្ងៃទី២៤ ខែមេសា ឆ្នាំ២០២៥នៅអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងតាមប្រព័ន្ធអនឡាយ( Zoom )៕

ថ្ងៃចន្ទ ៣កើត ខែចេត្រ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២៥

**ប្រធានអង្គប្រជុំ**

**បណ្ឌិត ឈឹម ឃិនដារ៉េត**

**បានពិនិត្យត្រឹមត្រូវ**

**ប្រធាននាយកដ្ឋានទាក់ទង និង ចលនាប្រភពធនធាន**

វេជ្ជ.ហួត សេរីវឌ្ឍ

អ្នកធ្វើរបាយការណ៍

**ស៊ុំ ផល្លា**